ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019, Fax: (855) 23 883 750
E-mail: comfrel@online.com.kh or comfrel@forum.org.kh Site: http://www.comfrel.org

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធុន សារាយ
Mr. THUN SARAY
ជាតំណាងទី១ និង
ប្រធាន ADHOC

លោកស្រី អ៊ុង ចាន់ថុល
Ms. OUNG Chanthol
ជាតំណាងទី២ និង
នាយិកា CWCC

លោក យឹម ប៉ូ
Mr. YIM Po អគ្គហិរញ្ញិក
និងនាយក CCPCR

លោក សុក សំអឿន
Mr. SOK Sam Oeun
នាយក CDP

លោកស្រី ទីវ សារ៉ាយ៉េត
Ms. TIV Sarayet
សហនាយិកា WMC

លោក យ៉ង់ គិមអេង
Mr. YONG Kim Eng
ប្រធាន KYA

លោក អ៊ុក វណ្ណះដេត
Mr. OUK Vandeth
នាយក LAC

លោក ស៊ីល វិនេត្រ
Mr. SIL Vinet នាយក SEDOC

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សេន សែត
Mr. SEN Set

លោក មុំ សារិន
Mr. MOM Sarin
នាយក KKKHRA

លោក ទូច ទុម
Mr. Touch Tum
នាយក VIGILANCE

ស.ប្រ.ក/លេខ ០៩/០៧ គ.ប.ស.យ/អ.ក

**សេចក្តីប្រកាសព័ត៌មាន**

**លទ្ធផលនៃការអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយ**

**ពីថ្ងៃទី ១៦-២២ ខែ មីនា ឆ្នាំ ២០០៧**

*ភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៧*

ខុមហ្វ្រែល បាន និងកំពុងធ្វើការអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចមួយចំនួនរួមមាន ទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍ស៊ីធីអិន វិទ្យុជាតិកម្ពុជាក៏រិត FM96MHz វិទ្យុជាតិក៏រិត AM918 KHz (ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកទាំង ៤ នេះបាននិងកំពុងត្រូវបានអង្កេតការផ្សាយចាប់ពីម៉ោង ១៧:០០ ដល់ម៉ោង ២៣:៣០ ជារៀងរាល់ថ្ងៃ) វិទ្យុបារាំងអន្តរជាតិ វិទ្យុអាស៊ីសេរី និងវិទ្យុសំលេងសហរដ្ឋអាមេរិក (វិទ្យុអន្តរជាតិទាំងបីនេះបាន និងកំពុងត្រូវបានអង្កេតការផ្សាយតាមកម្មវិធីរៀងរាល់យប់)។ ខុមហ្វ្រែល ក៏សង្កេតលើប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពផងដែរ មានសារព័ត៌មានរស្មីកម្ពុជា និងកោះសន្តិភាព។

## <u>លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយរដ្ឋ</u>

ក្នុងសប្តាហ៍ទីមួយនៃយុទ្ធនាការបោះឆ្នោតនេះ មានតែវិទ្យុជាតិកម្ពុជាក៏រិត **918 KHz តែមួយគត់ដែលបានធ្វើការផ្សព្វផ្សាយពីគណបក្សនយោបាយ ហើយក្នុងរយៈពេលដ៏ខ្លីទៀតផង** ខុសកាលពីរយៈពេលមុនយុទ្ធនាការ ដែលប្រព័ន្ធផ្សព្វផ្សាយរដ្ឋមានភាពលំអៀងទៅរកគណបក្សប្រជាជនកម្ពុជា។ ក្នុងនោះគណបក្សនយោបាយចំនួន ៣ គឺ គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម រង្ស៊ី ត្រូវបានឮឈ្មោះស្មើៗគ្នាគឺ២វិនាទី ទាក់ទងនឹងការធ្វើសេចក្តីរាយការណ៍ពីការបើកសម័យប្រជុំរបស់រដ្ឋសភា។ ចំណែកគណបក្សនរោត្តម រណឫទ្ធិ ត្រូវបានផ្សព្វផ្សាយច្រើនជាងគេគឺ ១ នាទី ២៤ វិនាទី ទាក់ទងនឹងការទទួចរកការអន្តរាគមន៍របស់សម្តេចក្រុមព្រះពីបរទេសទាក់ទងនឹងការកាត់ទោសរបស់ព្រះអង្គ។

### <u>កម្មវិធីផ្សព្វផ្សាយគោលនយោបាយរួមនៃគណបក្សនយោបាយ</u>[១]

កម្មវិធីនេះត្រូវបានផលិតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) និងចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចរបស់រដ្ឋទាំង៣។ ក្នុងកម្មវិធីនេះ គណបក្សនយោបាយទាំង ១២ ត្រូវបានផ្សព្វផ្សាយក្នុងរយៈពេលប្រហាក់ប្រហែលគ្នាគឺចន្លោះពី ៦%(ស្មើនឹង ២ម៉ោង ៨នាទី ៥២វិនាទី)ទៅប្រមាណ ១០%

---

១ *កម្មវិធីផ្សព្វផ្សាយគោលនយោបាយរួមនៃគណបក្សនយោបាយ* មិនត្រូវបានវិភាគខ្លឹមសារទេ (ចាត់ទុកក្នុងន័យអព្យាក្រឹត)។

(ស្មើនឹង ៣ ម៉ោង ២៣ នាទី ៥០ វិនាទី)។ កម្មវិធីនេះនៅក្នុងវិទ្យុ FM96MHz ត្រូវបានអាក់ខានការផ្សាយរយៈពេល ៤ ថ្ងៃ (ពីថ្ងៃទី ២០ ដល់ ២៣ ខែមីនា) ដោយសារតែប៉ុស្តិ៍នេះបានដាច់។ មានគណបក្សនយោបាយចំនួន៥ (គណបក្សប្រជាជនកម្ពុជា គណបក្សចំរើននិយមខ្មែរ គណបក្សរណសិរ្សសង្គមជាតិនិយម គណបក្សនរោត្តម រណប្ញទ្ធិ និងគណបក្សហ៊្វុនស៊ិនប៉ិច) ធ្លាប់បាននិយាយលើសពីពេលវេលាដែល គជប ផ្តល់ឱ្យ។

<u>កម្មវិធីព័ត៌មានសមធម៌នៅក្នុង ទទក (ផ្សាយក្រោយម៉ោងព័ត៌មាន)</u>

មានតែគណបក្សនយោបាយចំនួន ៩ ប៉ុណ្ណោះដែលត្រូវបានបង្ហាញ ឬឮឈ្មោះនៅក្នុងកម្មវិធីព័ត៌មានសមធម៌ក្នុងរយៈពេលអង្កេតនេះ។ មានគណបក្សនយោបាយចំនួន ៤ (គណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តម រណប្ញទ្ធិ) ត្រូវបានបង្ហាញនៅគ្រប់ការផ្សាយទាំងអស់។

ក្នុងរយៈពេលមួយសប្តាហ៍នេះ គណបក្សប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយ ២៩%(ស្មើនឹង ១៤នាទី ៥៩វិនាទី)។ គណបក្ស ហ៊្វុនស៊ិនប៉ិចបាន ២៥% (ស្មើនឹង ១២ នាទី ៤៣ វិនាទី)។ គណបក្ស នរោត្តម រណប្ញទ្ធិបាន ២០% (ស្មើនឹង ១០ នាទី ១២ វិនាទី)។ គណបក្ស សម រង្ស៊ី ត្រូវបានលើកឡើងប្រហែល ១៨% (ស្មើនឹង ៩ នាទី ១ វិនាទី)។ ចំណែកគណបក្សនយោបាយ ៥ ផ្សេងទៀត (គណបក្សចំរើនខ្មែរនិយម គណបក្សរណសិរ្សសង្គមជាតិនិយម គណបក្សហង្សដារាចលនាប្រជាធិបតេយ្យ គណបក្សសម្ព័ន្ធដើម្បីលទ្ធិប្រជាធិបតេយ្យ និងគណបក្សប្រជាធិបតេយ្យខ្មែរ) រួមគ្នាត្រូវបានឮឈ្មោះ និងបង្ហាញ ៨% (ស្មើនឹង ៤ នាទី ១ វិនាទី)។

ខ្លឹមសារ និងរូបភាពនៅក្នុងកម្មវិធីនេះមានភាពវិជ្ជមានសំរាប់គណបក្សប្រជាជនកម្ពុជា ដូចជាការលើកឡើងរបស់ពិធីករថា **ក្បួនដង្ហែរ និងការឃោសនារបស់គណបក្សប្រជាជនកម្ពុជាមានសណ្តាប់ធ្នាប់ល្អ ត្រឹមត្រូវ និងការលើកឡើងពីថ្ងៃ៧មករា** ខណៈដែលគណបក្សផ្សេងៗមិនត្រូវបានសរសើរថាមានសណ្តាប់ធ្នាប់ល្អនោះទេ។ **ការបង្ហាញរូបភាពក៏មានភាពវិជ្ជមានសំរាប់គណបក្សប្រជាជនកម្ពុជាផងដែរ** ដូចជាការរាំច្រៀងសប្បាយ និងការទះដៃអបអរសាទរដោយសមាជិកគណបក្សនេះ ខណៈដែលភាពអវិជ្ជមានរបស់គណបក្សនេះមិនត្រូវបានបង្ហាញ ឬឮឡើយ។ ចំណែកគណបក្សផ្សេងៗត្រូវបានផ្សព្វផ្សាយក្នុងខ្លឹមសារចំរុះ (អវិជ្ជមាន វិជ្ជមាន និង/ឬអព្យាក្រឹត)នៅក្នុងរយៈពេលអង្កេតនេះ ដូចជាការផ្សាយពី **ទំនាស់រវាងគណបក្សនរោត្តម រណប្ញទ្ធិ និងគណបក្សហ៊្វុនស៊ិនប៉ិច** ទាក់ទងនឹងការឃោសនាជាដើម។

ក្នុងកម្មវិធីនេះដដែល **ពិធីករមិនបានបែងចែងតួនាទីរដ្ឋ និងក្នុងគណបក្សរបស់បុគ្គលឱ្យបានដាច់នោះទេ** ដូចជាការផ្សាយរៀបរាប់ពីសម្តេច ជា ស៊ីម ជាប្រធានព្រឹទ្ធសភា តែសម្តីផ្ទាល់របស់សម្តេច **ជា ស៊ីម** គឺនិយាយក្នុងនាមប្រធាន

គណបក្សប្រជាជនកម្ពុជា។ ការបែងចែងមិនច្បាស់នេះ បាននាំមកការពន្យល់ថា ព័ត៌មានគឺនិយាយអំពីអ្នកដឹកនាំស្ថាប័នរដ្ឋ ប៉ុន្តែតាមពិតប្រាកដ វាគឺជាព័ត៌មានរបស់អ្នកដឹកនាំគណបក្សនយោបាយ។

ក្នុងរយៈពេលអង្កេតនេះ មានតែគណបក្សនយោបាយចំនួនតែ ៥ ប៉ុណ្ណោះ ដែលផ្លាកសញ្ញាត្រូវបានបង្ហាញគឺ គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សនរោត្តមរណឫទ្ធិ គណបក្សសម រង្ស៊ី និងគណបក្សរណសិរ្ស សង្គមជាតិនិយម។

ដោយសរុបការផ្សាយកម្មវិធីនេះទាំងនៅក្នុង ទទក វិទ្យុFM96MHz គណបក្សប្រជាជនកម្ពុជាត្រូវបានឮ និង បង្ហាញ ២៩% (ស្មើនឹង ១៤ នាទី ៥៤ វិនាទី)។ គណបក្ស ហ៊្វុនស៊ិនប៉ិច ទទួលបាន ២៥% (ស្មើនឹង ១២នាទី ៤៣វិនាទី)។ គណបក្ស នរោត្តម រណឫទ្ធិ បាន ២០% (ស្មើនឹង ១០នាទី ១២វិនាទី) និងគណបក្ស សម រង្ស៊ី ត្រូវបានឮ និងបង្ហាញ ប្រហែល ១៨% (ស្មើនឹង ៩ នាទី ១ វិនាទី)។ ចំណែកគណបក្សនយោបាយ៥ផ្សេងទៀតរួមគ្នា ត្រូវបានផ្សព្វផ្សាយ ៨% (ស្មើនឹង ៤ នាទី ១០ វិនាទី)។

**<u>លទ្ធផលអង្កេតទូរទស្សន៍ ស៊ី ធី អ៊ិន</u>**

**កម្មវិធីទេពកោសល្យ និងស្នាដៃរបស់បណ្តាញទូរទស្សន៍កម្ពុជា (ស៊ីធីអិន) នៅតែបន្តបង្ហាញ និងផ្សព្វផ្សាយពី គណបក្សគណបក្សប្រជាជនកម្ពុជាតែមួយគត់។កម្មវិធីដែលមានរយៈពេលមួយម៉ោងនេះនៅតែបន្តសម្ភាសន៍តែចៅសង្កាត់ មកពីគណបក្សប្រជាជនកម្ពុជាដែលបាននិយាយពីសមិទ្ធផលរបស់ខ្លួនដែលបានសាងសង់។ ពិធីករនៅក្នុងកម្មវិធីនេះនៅតែ បន្តនិយាយសរសើរដល់គណបក្សប្រជាជនកម្ពុជា ហើយបាននិយាយបង្អាប់ដល់គណបក្សមិនកាន់អំណាច។**

**<u>លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយ វិទ្យុអន្តរជាតិទាំងបី (RFI, RFA, VOA)</u>**

បើប្រៀបបញ្ចូលវិទ្យុអន្តរជាតិទាំងបីរួមគ្នាឃើញថា គណបក្សនយោបាយទាំង ១២ ត្រូវបានលើកឡើង និងផ្សព្វ-ផ្សាយ ក្នុងសប្តាហ៍ទី១នៃការឃោសនានេះ។ គណបក្សនយោបាយចំនួន ៤ (គណបក្សប្រជាជនកម្ពុជា គណបក្ស ហ៊្វុន-ស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ) នៅតែគ្របដណ្តប់ការផ្សាយនេះដដែល។ គណបក្ស សម រង្ស៊ី បាននាំមុខ ដោយ ត្រូវបានផ្សព្វផ្សាយជាង ២៤% (ស្មើនឹង ១ ម៉ោង ១៥នាទី ៣៨វិនាទី) នៃរយៈពេលសរុបផ្សាយពីគណបក្សនយោបាយ។ ចំណែកគណបក្សប្រជាជនកម្ពុជា ត្រូវបានផ្សព្វផ្សាយច្រើនលំដាប់ទីពីរគឺប្រហែល ២៤% (ស្មើនឹង ១ម៉ោង ១៣នាទី ២៥ វិនាទី)។ គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានប្រហែល១៧%(ស្មើនឹង ៥១នាទី ៣៧វិនាទី) ហើយគណបក្សនរោត្តម រណឫទ្ធិ ត្រូវបានផ្សព្វផ្សាយ ១៥% (ស្មើនឹង ៤៦នាទី ២៧វិនាទី)។ ចំណែកគណបក្សចំនួន ៨ ទៀត រួមគ្នាត្រូវបានផ្សព្វផ្សាយ ២០% (ស្មើនឹង ១ ម៉ោង ១៦ នាទី ៤៧ វិនាទី)។

ការផ្សព្វផ្សាយភាគច្រើនគឺ ក្នុងន័យអព្យាក្រឹត។ ការផ្សព្វផ្សាយបែបវិជ្ជមានតិចតួច សំរាប់គណបក្សនយោបាយមួយចំនួនផងដែរ តែការផ្សព្វផ្សាយបែបអវិជ្ជមាន មានចំពោះតែគណបក្សនយោបាយ ៣ ប៉ុណ្ណោះ។ ភាពអវិជ្ជមានរបស់គណបក្សប្រជាជនកម្ពុជាមានច្រើនជាងគេប្រមាណ ១៣% (ស្មើនឹង ៩នាទី ៥វិនាទី) នៃការផ្សាយពីគណបក្សនេះសរុប ដូចជា ការផ្សាយពីភាពរំខានរបស់គនបក្សប្រជាជនកម្ពុជាចំពោះការឃោសនា របស់គណបក្សផ្សេងៗទៀត។ គណបក្ស សម រង្ស៊ី ត្រូវបានផ្សព្វផ្សាយបែបអវិជ្ជមានប្រមាណ ៤% (ស្មើនឹង ៣នាទី ២០វិនាទី) ដូចជាការផ្សាយ និងគណបក្ស នរោត្ត រណប្ញទ្ធិ ទទួលបានការផ្សព្វផ្សាយបែបអវិជ្ជមាននេះប្រមាណ ៣% (ស្មើនឹង ១នាទី ៣៤វិនាទី)។

វិទ្យុអន្តរជាតិបានផ្តោតការផ្សាយខ្លាំងរបស់ខ្លួនទៅលើព្រឹត្តិការណ៍នានាទាក់ទងនឹងការឃោសនាបោះឆ្នោត ដូចជា អំពើហឹង្សា ការរារាំង និងការផ្សព្វផ្សាយពីគោលនយោបាយរបស់គណបក្សនយោបាយផងដែរ។

## <u>លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចទាំងអស់</u>

សរុបលទ្ធផលនៃការអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចទាំងអស់បានបង្ហាញឱ្យឃើញថា ក្នុងសប្តាហ៍ទីមួយនៃការឃោសនានេះ គណបក្សនយោបាយទាំង ១២ ទទួលបានការផ្សព្វផ្សាយច្រើនធៀបទៅនឹងការផ្សាយមុនៗ។ ក្នុងនោះ គណបក្សនយោបាយចំនួន ៤ ត្រូវបានផ្សព្វផ្សាយច្រើនជាងគេ។ គណបក្សប្រជានជនកម្ពុជា ទទួលបានប្រមាណ ១៤% (ស្មើនឹង ៣ ម៉ោង ៨នាទី ៣៩វិនាទី)។ គណបក្ស សម រង្ស៊ី ១៣% (ស្មើនឹង ៣ម៉ោង ១នាទី ៤០វិនាទី) គណបក្ស នរោត្តមរណប្ញទ្ធិ ១២% (ស្មើនឹង ២ម៉ោង ៤៧នាទី ៤៦វិនាទី) និងគណបក្ស ហ៊្វុនស៊ិនប៉ិច ប្រហែល១២% (ស្មើនឹង ២ម៉ោង ៤៣វិនាទី ១៥វិនាទី។ ចំណែកគណបក្សនយោបាយ ៨ ផ្សេងទៀត ដែលទទួលបានការផ្សព្វផ្សាយដ៏តិចតួចបំផុត មុនពេលយុទ្ធនាការឃោសនាបោះឆ្នោតចាប់ផ្តើម ក៏ទទួលបានការផ្សព្វផ្សាយច្រើនផងដែរចន្លោះពី ៥% (ស្មើនឹង ១ម៉ោង ១២នាទី ២២វិនាទី) ទៅ ៧% (ស្មើនឹង ១ម៉ោង ៤៣នាទី ៤២វិនាទី)។

ខ្លឹមសារផ្សព្វផ្សាយភាគច្រើនលើសលប់គឺក្នុងន័យអព្យាក្រឹត។ ការផ្សព្វផ្សាយបែបអវិជ្ជមាន មានតិចតួចសំរាប់គណបក្សនយោបាយចំនួន ៣ គឺ គណបក្សប្រជាជនកម្ពុជា ៥% (ស្មើនឹង ៩នាទី ៥៩វិនាទី) នៃការផ្សាយសរុបពីគណបក្សនេះដូចជា ការផ្សព្វផ្សាយថា សមាជិកគណបក្សប្រជាជនកម្ពុជាព្រួតគ្នាវាយសកម្មជនគណបក្ស សម រង្ស៊ី ជាដើម។ គណបក្ស សម រង្ស៊ី ទទួលការផ្សាយបែបអវិជ្ជមាន ២% (ស្មើនឹង ៣នាទី ២០វិនាទី) និងគណបក្ស នរោត្តម រណប្ញទ្ធិ ១% (ស្មើនឹង ១នាទី ៣៤វិនាទី)។ ការផ្សព្វផ្សាយបែបវិជ្ជមាន មានចំពោះគណបក្សមួយចំនួនផងដែរ។ ក្នុងនោះ គណបក្សប្រជាជនកម្ពុជាទទួលបានការផ្សព្វផ្សាយបែបវិជ្ជមាននេះច្រើនជាងគេ (ប្រមាណ៨% ស្មើនឹង ១៥នាទី ៤៣វិនាទី នៃរយៈពេលសរុបផ្សាយពីគណបក្សនេះ) និងគណបក្ស សម រង្ស៊ី ទទួលបានប្រហែល ៨% (ស្មើនឹង ១៤នាទី ១៤វិនាទី) ដូចជាការផ្សាយពីការគាំទ្ររបស់ប្រជាពលរដ្ឋចំពោះការឃោសនារបស់គណបក្សនេះជាដើម។ ចំណែកគណបក្សនយោ-

បាយ ៥ ទៀតទទួលបានការផ្សព្វផ្សាយបែបវិជ្ជមាននេះច្រើនបំផុតប្រមាណត្រឹម ១% ប៉ុណ្ណោះ (ធៀបទៅ នឹងរយៈពេលនៃការផ្សាយសរុបរបស់គណបក្សនីមួយៗ)។

វេទិកាដែលមានលក្ខណៈរជដែកដេញដោលគ្នារវាងបេក្ខជនមេឃុំរឺចៅសង្កាត់ ត្រូវបានផ្សាយដោយវិទ្យុអាស៊ីសេរីតែមួយប៉ុណ្ណោះដែលក្នុងនោះបេក្ខជនមកពីគណបក្សប្រជាជនកម្ពុជាបាននិយាយរហូតដល់ ៨ នាទី ៣៥ វិនាទី។ បេក្ខជនមកពីគណបក្ស នរោត្តម រណឫទ្ធិ និយាយបាន ៥នាទី ៣៩វិនាទី។ បេក្ខជនមកពីគណបក្ស ហ៊្វុនស៊ិនប៉ិច និយាយបាន ៤នាទី ៥៨វិនាទី និងមកពីគណបក្ស សម រង្ស៊ីបាន ៣នាទី ១៥វិនាទី។

កម្មវិធី ស្ប៉ត(រឿងខ្លី) និងព័ត៌មានស្តីពីការបោះឆ្នោតត្រូវបានផ្សព្វផ្សាយរយៈពេល ៦ម៉ោង ៤៤នាទី ៣វិនាទី។ នៅក្នុងអំឡុងពេលនៃការឃោសនានេះ គជប និងអង្គការមិនមែនរដ្ឋាភិបាលបានផលិតស្ប៉ត និងបទចំរៀងជាច្រើនថែមទៀតទាក់ទងនឹងការបោះឆ្នោត ដូចជាជំរុញប្រជាពលរដ្ឋទៅបោះឆ្នោតដោយឆន្ទៈ និងប្រាប់ពេលវេលានៃការបោះឆ្នោតជាដើម។ ស្ប៉តរបស់គជបក៏ត្រូវបានផ្សាយតាមរយៈទូរទស្សន៍ឯកជនស៊ីធីអិនដែរ ដែលកាលពីមុនយុទ្ធនាការឃោសនាប៉ុស្តិ៍នេះមិនដែលផ្សាយស្ប៉តអប់រំអ្នកបោះឆ្នោតឡើយក្នុងរយៈពេលអង្កេត។

បញ្ហាស្ត្រីក្នុងវិស័យនយោបាយ ត្រូវបានផ្សព្វផ្សាយដោយវិទ្យុអាស៊ីសេរីតែមួយប៉ុណ្ណោះដែលមានរយៈពេល១នាទី ៨វិនាទី ក្នុងឱកាសនៅក្នុងវេទិការបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI)។

ក្នុងពេលវេលាអង្កេតនេះ ស្ត្រីជាបេក្ខជនសំរាប់ឈរឈ្មោះបោះឆ្នោត ឬមេឃុំ ចៅសង្កាត់ជាស្ត្រីត្រូវបានផ្សព្វផ្សាយ ឬលើកឡើងក្នុងរយៈពេល ១៤នាទី ៥៤វិនាទី ដូចជាការចាក់ផ្សាយពី សមត្ថភាពការងារមេឃុំស្រីដែលផលិតដោយមជ្ឈមណ្ឌលព័ត៌មានស្ត្រីជាដើម។

ការលើកឡើងពីជនពិការក្នុងវិស័យនយោបាយមិនត្រូវបានផ្សព្វផ្សាយទេក្នុងរយៈពេលអង្កេតនេះ។

ការអំពាវនាវអោយទៅបោះឆ្នោត ឬការផ្សាយថាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយច្បាស់លាស់ត្រូវបានផ្សាយតែនៅក្នុងវិទ្យុអាស៊ីសេរីតែមួយប៉ុណ្ណោះ ដូចជាការចាក់ផ្សាយការអំពាវនាវរបស់គណបក្ស សម រង្ស៊ី សុំអោយប្រជាពលរដ្ឋបោះឆ្នោតអោយខ្លួនវិញ ដើម្បីផ្លាស់ប្តូរជីវិភាពរស់នៅ។ ការអំពាវនាវបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជាក៏ត្រូវបានផ្សាយដោយអាស៊ីសេរីផងដែរ។

**<u>លទ្ធផលនៃប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព (កោះសន្តិភាព និងរស្មីកម្ពុជា)</u>**

មានតែគណបក្សនយោបាយចំនួន ៤ ប៉ុណ្ណោះ គឺគណបក្សប្រជាជនកម្ពុជា គណបក្ស ហ៊្វុនស៊ិនប៉ិច គណបក្សនរោត្តម រណឫទ្ធិ និងគណបក្ស សម រង្ស៊ី ដែលត្រូវបានផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព (កោះសន្តិភាព និងរស្មីកម្ពុជា) ទាំងពីររួមគ្នាក្នុងសប្តាហ៍ទីមួយនៃយុទ្ធនាការឃោសនាបោះឆ្នោត។ គណបក្សប្រជាជនកម្ពុជា ត្រូវបានផ្សព្វ-ផ្សាយច្រើន ជាងគេគឺ ៤៤% (ស្មើនឹង ៧អត្ថបទ)។ គណបក្ស សម រង្ស៊ីទទួលបាន ២៥% (ស្មើនឹង ៤អត្ថបទ)។ គណបក្ស ហ៊្វុនស៊ិនប៉ិច ត្រូវបានលើកឡើង ១៨% (ស្មើនឹង ៣អត្ថបទ) និងគណបក្ស នរោត្តមរណឫទ្ធិត្រូវបានផ្សព្វផ្សាយ ១២% (ស្មើនឹង ២អត្ថបទ)។

ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពទាំងពីរនេះបានផ្សព្វផ្សាយភាគច្រើនពីភាពវិជ្ជមានរបស់គណបក្សប្រជាជនកម្ពុជា ដែលមានរហូតដល់ទៅ ៨៦% (ស្មើនឹង ៦អត្ថបទ នៃការផ្សាយពីគណបក្សនេះសរុប) ហើយភាពអវិជ្ជមានរបស់គណបក្សនេះមិនត្រូវបានលើកឡើងឡើយក្នុងរយៈពេលអង្កេតនេះ។ ការផ្សាយភាគច្រើនគឺជាព័ត៌មានពីយុទ្ធនាការរបស់គណបក្សនេះ ដែលទទួលបានការគាំទ្រពីប្រជាពលរដ្ឋជាដើម។

គណបក្សនយោបាយបីផ្សេងទៀតត្រូវបានផ្សព្វផ្សាយបែបអព្យាក្រឹត និងបែបវិជ្ជមានផងដែរ ដែលខុសពីមុនយុទ្ធនាការដែលគណបក្សទាំងនេះត្រូវគ្របដណ្តប់ដោយព័ត៌មានបែបអវិជ្ជមាន។

អត្ថបទដែលមានលក្ខណៈអប់រំអ្នកបោះឆ្នោតត្រូវបានផ្សព្វផ្សាយចំនួនតែ ១ អត្ថបទប៉ុណ្ណោះ ក្នុងសារព័ត៌មានកោះសន្តិភាពទាក់ទងនឹងការប្រកាសរបស់ គជប ក្នុងការបញ្ជូនសន្លឹកឆ្នោតទៅតាមបណ្តាខេត្ត/ក្រុងនានា។

អត្ថបទដែលមានការអំពាវនាវជាចំហរឱ្យបោះឆ្នោតជូនគណបក្សនយោបាយមានចំនួន២។ ក្នុងអត្ថបទទាំងពីរនេះគឺជាការគាំទ្រ និងការអំពាវនាវបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។

**សូមអរគុណ!**

*សំរាប់ព័ត៌មានលំអិតសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ០១២ ៨៤៥ ០៩១
- លោក **កុយ ច័ន្ទដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ០១២ ៨៤៦ ២១១